# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ វត្តខ្មែរកាណាដា ជុំវិញការប្តឹងផ្តល់គ្នារវាងគណបក្សនយោបាយខ្មែរទាំងបីនៅកម្ពុជា

**Website: www.hoksavann.org**

ថ្ងៃទី៩ តុលា ២០០៤

ការប្តឹងផ្តល់គ្នារវាងគណបក្សទាំងបី កើតឡើងក្រោយពេលដែលរដ្ឋាភិបាលកញ្ចប់បានបង្កើតឡើង ។ គណបក្សប្រជាជនកម្ពុជានិងគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលរួមគ្នាធ្វើរដ្ឋាភិបាលចំរុះ ពុំមានការប្តឹងផ្តល់គ្នាទេ ឯការប្តឹងផ្តល់គ្នាគឺកើតឡើងរវាងគណបក្សទាំងពីរនេះ ជាមួយគណបក្សសម-រង្ស៊ី ។ ការវិវាទគ្នានេះ កើតអំពីមូលហេតុចែកអំណាចពុំត្រូវគ្នា ។ គណបក្សទាំងពីរ គឺគណបក្សប្រជាជនកម្ពុជានិងគណបក្សហ្វ៊ុនស៊ិនប៉ិច ពុំមានការវិវាទគ្នា មកអំពីចែកអំណាចត្រូវគ្នា ទោះបីគណបក្សនីមួយៗក្នុងបណ្តាគណបក្សទាំងពីរនេះមានកំហុស ក៏បិទភ្នែកមិនចោទប្រកាន់គ្នាទៅវិញទៅមកឡើយ ដូចសុភាសិតខ្មែរថា ឃ្លានឆ្ងាញ់ស្រឡាញ់ល្អ ។ ដូចនេះគូប្រយុទ្ធនៅសល់តែពីរ គឺគណបក្សសម-រង្ស៊ីជាមួយរដ្ឋាភិបាលចំរុះ ។ ប្រធានគណបក្សសម-រង្ស៊ីតែងចោទទៅលើប្រធានគណបក្សទាំងពីរថាប្រព្រឹត្តអំពើពុករលួយ ។ ឯមេគណបក្សទាំងពីរ មិនចង់ឲ្យគណបក្សប្រឆាំងចោទ តែងចោទតបវិញ ។ ការចោទគ្នាទៅវិញទៅមកនេះ ក្លាយទៅជាទម្លាប់របស់អ្នកដឹកនាំខ្មែរ ។ គណបក្សសម-រង្ស៊ីនិងគណបក្សហ្វ៊ុនស៊ិនប៉ិចធ្លាប់ធ្វើសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យជាមួយគ្នា ឥឡូវនេះក្លាយជាសត្រូវនឹងគ្នា ។ បើប្រៀបធៀបគណបក្សទាំងបី គណបក្សនីមួយៗតែងមានវិវាទផ្ទៃក្នុងដូចគ្នា គ្រាន់តែទំនាស់នោះធូរស្រាលជាងគ្នានិងមានការជំទាស់ជាមួយគណបក្សផ្សេងទៀត ។ ចំពោះព្រឹត្តិការណ៍តែងតែកើតមានបែបនេះនៅប្រទេសកម្ពុជា តើគណបក្សណាឆ្លាតជាងដើម្បីទាញយកប្រយោជន៍សំខាន់សំរាប់គណបក្សខ្លួន ។ គណបក្សប្រជាជនកម្ពុជាពិតជាឆ្លាតជាងគណបក្សពីរទៀត ព្រោះអ្វី ព្រោះថាគណប្រជាជនកម្ពុជាពិតជាមានវិវាទផ្ទៃក្នុងដូចគណបក្សពីរទៀតដែរ ប៉ុន្តែគេចេះបិទបាំងមិនឲ្យលេចឮបែកចេញពីមាត់គេឡើយ គឺគេលាក់ការមិនឲ្យអ្នកដទៃដឹងនូវកិច្ចការផ្ទៃក្នុងរបស់គេឡើយ គឺគេចេះបិទស្ទើរតែអ្នកដទៃមើលមិនឃើញស្នាម ហើយទីបំផុតគេរួមគ្នាវិញដើម្បីអាយុជីវិតបក្ស ។ មធ្យោបាយដែលអនុវត្តបានជោគជ័យនេះ ដោយសារតែប្រតិបត្តិតាមដំបូន្មានរបស់លោកគ្រូឧបជ្ឈាយ៍បរទេសនៅទិសខាងកើត ។ ដូច្នេះគណបក្សប្រជាជនកម្ពុជា ដែលជាអតីតគណបក្សកុម្មុយនិស្តនេះ គេយកប្រយោជន៍បក្សដាក់ពីមុខជាអាទិភាពទី១ ត្រូវតែគិតគូរជាងប្រយោជន៍ផ្ទាល់ខ្លួន ។ បែរមកមើលគណបក្សពីរទៀត គឺគណបក្សសម-រង្ស៊ីនិងគណបក្សហ្វ៊ុនស៊ិនប៉ិចវិញ គណបក្សទាំងពីរនេះពេលដែលរួបរួមគ្នាធ្វើសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជា បានប្តេជ្ញាចិត្តថា បើទៅទីណាត្រូវទៅជាមួយគ្នា បើមិនទៅមិនទៅជាមួយគ្នា បានសេចក្តីថា បើចូលធ្វើរាជរដ្ឋាភិបាលត្រូវចូលជាមួយគ្នា បើមិនចូលមិនចូលដូចគ្នា ។ ឥឡូវនេះ អំពើប្រព្រឹត្តផ្ទុយពីពាក្យប្តេជ្ញាចិត្ត គឺបក្សយើងទាំងពីរត្រូវតែបែកគ្នា ត្រូវតែចែកផ្លូវគ្នាដើរ ហើយយើងត្រូវតែចោទរកកំហុសគ្នាទៅវិញទៅមកថែមទៀត ។ នៅពេលដែលគណបក្សសម-រង្ស៊ីនិងគណបក្សហ្វ៊ុនស៊ិនប៉ិចកំពុងខាំគ្នា គណបក្សប្រជាជនកម្ពុជាឱបដៃញញឹមដោយចិត្តរំភើប ដោយបំណងរបស់គេបានសំរេចហួសពីការស្មាន ព្រោះបំណងបំបែកគណបក្សទាំងពីរនេះឲ្យបែកគ្នា កុំឲ្យចងសម្ព័ន្ធមិត្តនឹងគ្នាបាន ព្រោះបើគណបក្សសម-រង្ស៊ីនិងគណបក្សហ្វ៊ុនស៊ិនប៉ិចរួមគ្នា គណបក្សប្រជាជនកម្ពុជាពិបាកទប់ទល់ណាស់ ឥឡូវនេះមិនត្រឹមតែបែកគ្នាទេ ថែមទាំងប្តឹងគ្នាទៅវិញទៅមកទៀត ។ គណបក្សប្រជាជនកម្ពុជាទាញយកគណបក្សហ្វ៊ុនស៊ិនប៉ិចធ្វើជាដៃគូ ធ្វើរដ្ឋាភិបាលចំរុះ ព្រោះគណបក្សប្រជាជនកម្ពុជាដឹងចរិតមេគណបក្សហ្វ៊ុនស៊ិនប៉ិចនេះច្បាស់ណាស់ ព្រោះធ្លាប់ធ្វើការជាមួយគ្នាពីរអាណត្តិមកហើយ គឺមេបក្សនេះស្រណុកគេបន្ទន់ចិត្តណាស់ គ្មានគោលជំហរខ្លួនឯងច្បាស់លាស់ទេ ។ ចំពោះប្រធានគណបក្សសម-រង្ស៊ីវិញ ពុំបានចូលរួមរដ្ឋាភិបាលចំរុះទេ ទំនងជាគណបក្សហ្វ៊ុនស៊ិនប៉ិចពុំព្រមឲ្យចំនួនសមាជិករដ្ឋាភិបាលតាមការសុំរបស់គណបក្សខ្លួន ។ កាលពីមុន គណបក្សសម-រង្ស៊ីបានអនុញ្ញាតឲ្យប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច តំណាងខ្លួនក្នុងការចរចាជាមួយគណបក្សប្រជាជនកម្ពុជា ដើម្បីបង្កើតរដ្ឋាភិបាលចំរុះ ហើយគណបក្សសម-រង្ស៊ីចូលតាមទ្វារគណបក្សហ្វ៊ុនស៊ិនប៉ិច ពេលដែលពុំបានសំរេចតាមពាក្យសុំ គណបក្សសម-រង្ស៊ីក៏ឈប់ចូលរួមរដ្ឋាភិបាលចំរុះនោះតែម្តងទៅ ។ សូម្បីតែគណៈកម្មាធិការ៩នៅក្នុងរដ្ឋសភា ដែលតាមធម្មតាជាគណៈកម្មាធិការចំរុះ ចេញពីគណបក្សដែលមានតំណាងរាស្ត្រក្នុងរដ្ឋសភា ក៏គេពុំឲ្យគណបក្សសម-រង្ស៊ីចូលរួមដែរ ។ លទ្ធផលនេះកើតឡើង ដោយសារតែកំហុសមេគណបក្សសម-រង្ស៊ីខ្លួនឯង ទុកចិត្តខ្លាំងពេកទៅលើប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច ឲ្យសំរេចកិច្ចការសំខាន់ៗជំនួសខ្លួន ក្នុងការបង្កើតរដ្ឋាភិបាលចំរុះជាមួយគណបក្សប្រជាជនកម្ពុជា។ លុះដល់គេក្បត់ពុំដើរតាមបំណងរបស់ខ្លួន ទើបក្តៅក្រហាយស្តាយក្រោយ ក៏កើតការប្តឹងផ្តល់គ្នាទៅវិញទៅមកយ៉ាងនេះទៅ ។ ពេលនេះគេឃើញការប្តឹងផ្តល់គ្នា បញ្ចេញសកម្មភាពខ្លាំងចំពោះតែគណបក្សពីរ ដែលធ្លាប់ជាសម្ព័ន្ធភាពជាមួយគ្នា គឺគណបក្សសម-រង្ស៊ីនិងគណបក្សហ្វ៊ុនស៊ិនប៉ិច ឯគណបក្សប្រជាជនកម្ពុជាហាក់ដូចជាសម្ងំស្ងៀមមួយពេល។ គួរកត់សម្គាល់ថា គណបក្សទាំងពីរបានងាកមករកផ្លូវច្បាប់ផ្លូវតុលាការជាមធ្យោបាយដោះស្រាយទំនាស់ ជាជាងប្រើអំពើហឹង្សាមានលួចសម្លាប់គ្នាជាដើម ។ បើមានការរិះគន់ អ្នកដែលត្រូវគេរិះគន់គួរស្រាយបំភ្លឺតាមលិខិតនិងតាមប្រព័ន្ធពត៌មាន ដូចជាវិទ្យុ ទូរទស្សន៍ សារពត៌មានជាដើម ប្រសើរជាងការប្តឹងផ្តល់គ្នា ព្រោះនាំឲ្យមានបញ្ហាវែងឆ្ងាយទៅទៀត ។ បុគ្គលសាធារណៈដែលបំរើរដ្ឋនឹងជៀសវាងពុំផុតពីការរិះគន់ឡើយ ព្រោះខ្លួនជាភ្នាក់ងារដែលប្រជាពលរដ្ឋប្រគល់មុខនាទីឲ្យបំរើគេ ស៊ីប្រាក់ខែប្រជាពលរដ្ឋ បើសកម្មភាពណាដែលរដ្ឋាភិបាលអនុវត្តហើយ ប្រជាពលរដ្ឋមើលឃើញថា ជាសកម្មភាពធ្វើឲ្យខូចប្រយោជន៍ជាតិ ខូចប្រយោជន៍ប្រជាពលរដ្ឋ ប្រជាពលរដ្ឋអាចបញ្ចេញមតិដោយផ្ទាល់មាត់ ដោយលិខិតឈានរហូតដល់ការធ្វើបាតុកម្ម ជារបៀបធ្វើសំណូមពរឲ្យរដ្ឋាភិបាលអនុវត្តកិច្ចការបំរើផលប្រយោជន៍គេ ។ បើមិនចង់ឲ្យគេរិះគន់ មានតែកុំទៅកាន់ការរដ្ឋ ហើយបើបំរើការរដ្ឋពុំបានតទៅទៀតទេ គួរតែចុះចេញពីតំណែងដោយស្ម័គ្រចិត្តក្នុងកិត្តិយស កុំឲ្យធ្វើឲ្យខូចប្រយោជន៍ជាតិ ហើយនៅតែក្រាញអំណាចរហូតប្រើអំពើហឹង្សា ដើម្បីការពារអំណាចរបស់ខ្លួ-

ន ។ ជុំវិញការប្ដឹងផ្ដល់គ្នានេះ តុលាការក្រុងភ្នំពេញដែលគេដឹងទូទៅថា ជាតុលាការពុករលួយ ជាតុលាការពុំឯករាជ្យ ស្ថិតនៅក្រោមអំណាចអ្នកកាន់អំណាច បានធ្វើសំណើទៅសភា ឲ្យដកអភ័យឯកសិទ្ធិពីតំណាងរាស្ត្រម្នាក់របស់គណបក្សសម-រង្ស៊ី ដែលត្រូវប្រធានបក្សហ៊ុនសុិនប៉ិច ចោទថាបានបរិហារកេរ្តិ៍ ។ ការគ្រាន់តែបញ្ចេញទស្សនៈដោយសង្ស័យតាមអ្នកជំនាញការខាងច្បាប់ពោលថា មិនត្រូវដកអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រទេ ព្រោះខុសនឹងច្បាប់រដ្ឋធម្មនុញ្ញត្រង់មាត្រា៨០ជំពូកទី៧ ចែងថា «តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។ តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។ល។» ជាអយុត្តិធម៌ទៀតត្រង់តុលាការ មិនបានសុំដកអភ័យឯកសិទ្ធិពីប្រធានហ៊ុនសុិនប៉ិច ត្រូវប្រធានគណបក្សសម-រង្ស៊ី ចោទថាប្រព្រឹត្តអំពើពុករលួយ ដើម្បីធ្វើការអង្កេតមានភាពស្មើគ្នាទេ ។ មានភាពលំអៀងមួយទៀតរបស់តុលាការក្រុងភ្នំពេញ គឺបានកោះហៅប្រធានគណបក្សសម-រង្ស៊ីទៅសួរដល់ទីចាត់ការរបស់ខ្លួន ប៉ុន្តែប្រមុខដឹកនាំរដ្ឋាភិបាលដែលត្រូវជាប់ចោទដែរនោះ តុលាការមិនបានកោះហៅឲ្យមកទីចាត់ការរបស់ខ្លួនទេ បែរជាខ្លួនទៅសួរដល់ទីចាត់ការរបស់គេទៅវិញ ។

វិធានការដ៏សំខាន់ដើម្បីជៀសវាងការចោទប្រកាន់គ្នាទៅវិញទៅមកអំពីអំពើពុករលួយនេះ សមាជិកនៃរដ្ឋាភិបាល ប្រធានសភា ព្រឹទ្ធសភាជាដើម គប្បីសំអាតខ្លួនឯង ដោយសូមប្រកាសទ្រព្យសម្បត្តិរៀងខ្លួននៅពេលឡើងកាន់តំណែង និងពេលចុះចេញពីតំណែង ។ អ្នកសង្កេតការណ៍ឯករាជ្យបញ្ចេញទស្សនៈថា ខ្មែរពុំអាចបំបាត់ភាពក្រីក្រនៃប្រជាពលរដ្ឋខ្មែរបានឡើយ បើពុំកំចាត់អំពើពុករលួយឲ្យទាន់ពេលវេលាទេ ។ ឯច្បាប់កំចាត់អំពើពុករលួយ ក៏ពុំឃើញអនុម័តចេញឲ្យប្រើនៅឡើយ ។ ត្រង់នេះ ស្របតាមព្រះពុទ្ធសាសនាថា បើមានការងារស្អាតបរិសុទ្ធ ទើបអ្វីទាំងអស់បានចំរើនលូតលាស់ ។៚

❑